**បុណ្យរំលឹកសន្តអូគូស្តាំង ជាអភិបាល និងគ្រូបាធ្យាយនៃព្រះសហគមន៍**
**ព្រះសហគមន៍សន្តអូគូស្តាំង កំពត**
**ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២១**

**"សមត្ថភាព"**

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះនៅក្នុងគម្ពីរដំណឹងល្អ ព្រះយេស៊ូបានបង្ហាញអំពីបុរសបីនាក់ ម្នាក់ៗដូចជាព្រះយេស៊ូបានទទួលស្គាល់អំពីសមត្ថភាព។ អ្នកដែលមានសមត្ថភាពច្រើនបានទទួលប្រាក់ប្រាំណែន អ្នកដែលមានសមត្ថភាពល្មមបានទទួលពីរណែន អ្នកដែលមានសមត្ថភាពខ្សោយជាងគេបានទទួលប្រាក់តែមួយណែន។ នៅក្នុងពិភពលោក យើងដឹងថាមនុស្សយើងមានសមត្ថភាពខុសៗគ្នា នៅក្នុងព្រះសហគមន៍ក៏ដូចគ្នាដែរ។ ប៉ុន្តែ អ្វីដែលសំខាន់គឺមិនមែនសមត្ថភាពដែលយើងមាន សំខាន់គឺរបៀបដែលយើងប្រើសមត្ថភាពរបស់យើង ដែលជាព្រះណោយទានយ៉ាងពិសេសដែលយើងបានទទួលពីព្រះជាម្ចាស់ ដើម្បីឱ្យយើងយកចិត្តទុកដាក់ ដើម្បីឱ្យសមត្ថភាពរបស់យើង កម្លាំងរបស់យើង សេចក្តីស្រឡាញ់របស់យើង អំណោយទានដែលយើងទទួលពីព្រះជាម្ចាស់រីកចម្រើន។

អ្នកដែលបានច្រើនរីកចម្រើនគុណជាពីរ អ្នកដែលបានល្មមក៏បានរីកចម្រើនគុណជាពីរដូចគ្នា ប៉ុន្តែបញ្ហាគឺអ្នកដែលមានសមត្ថភាពតិចជាងគេ សមត្ថភាពរបស់គាត់មិនចង់ឱ្យលូតលាស់ រីកចម្រើនថែមទៀត ផ្ទុយទៅវិញគាត់កប់សមត្ថភាពរបស់គាត់នៅក្នុងដី។ ថ្ងៃនេះ ដែលយើងគោរពសន្តអូគូស្តាំង គាត់ជាមនុស្សម្នាក់ដែលបានទទួលកម្លាំង សមត្ថភាពយ៉ាងច្រើននៅក្នុងការសិក្សានៅក្នុងការស្វែងយល់អំពីទស្សនៈវិជ្ជា អំពីគណិតវិជ្ជាដែលមានចំណេះដឹងយ៉ាងខ្ពស់រហូតដល់គាត់ជាប់ជាមួយព្រះជាម្ចាស់។ នៅពេលគាត់រកឃើញព្រះជាម្ចាស់នៅក្នុងជីវិតរបស់គាត់ ណែនាំឱ្យគាត់ភ្ញាក់ គាត់បានរកឃើញព្រះជាម្ចាស់ហើយ "**ខ្ញុំបានដើរតាមព្រះជាម្ចាស់ជាយូរឆ្នាំមកហើយ ប៉ុន្តែរកមិនឃើញ**"។ នៅពេលគាត់រកឃើញព្រះជាម្ចាស់ តាមពិតគាត់មានអារម្មណ៍ថា ព្រះជា

ម្ចាស់បានរៀបចំទីលំនៅនៅក្នុងដួងចិត្តរបស់គាត់ពីយូរមកហើយ។ នៅពេលនោះ សមត្ថភាពរបស់គាត់ដូចជាបានរីកចម្រើនលូតលាស់។ នៅពេលគាត់ក្លាយជាលោកអភិបាល គាត់បានសរសេរសៀវភៅរាប់រយក្បាល គាត់បានរៀបចំធម្មទេសនាយ៉ាងច្រើន ដើម្បីណែនាំឱ្យព្រះសហគមន៍របស់គាត់ ឱ្យគ្រីស្តបរិស័ទរបស់គាត់បានរីកចម្រើននៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។

យើងនិយាយអំពីរឿងនៅឆ្នាំ៣០០ជាង មានន័យថាជាង១៧០០ឆ្នាំមុន ប៉ុន្តែសព្វថ្ងៃព្រះសហគមន៍របស់យើងបានទទួលឥទ្ធិពលយ៉ាងច្រើនពីសន្តអូគូស្តាំង។ ដោយសារសន្ត អូគូស្តាំង បានទទួលស្គាល់អំពីអំណោយទានដែលគាត់បានទទួលពីព្រះជាម្ចាស់ និងបានណែនាំឱ្យព្រះអំណោយទាននេះលូតលាស់នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។

ដូច្នេះថ្ងៃនេះ យើងអធិដ្ឋានដើម្បីឱ្យយើងជាគ្រីស្តបរិស័ទនៅបច្ចុប្បន្ននេះ ជាពិសេសនៅក្នុងសម័យកូវីដ-១៩ ឱ្យយើងពិនិត្យមើលគ្រប់សមត្ថភាព គ្រប់អំណោយ គ្រប់កម្លាំងដែលយើងទទួលពីព្រះជាម្ចាស់ និងណែនាំឱ្យសមត្ថភាព អំណោយ កម្លាំងដែលយើងបានទទួលពីព្រះជាម្ចាស់រីកចម្រើន កុំឱ្យយើងកប់នៅក្នុងដី។ ជាពិសេសនៅក្នុងពេលវេលាកូវីដ-១៩នេះ ជួនកាលណែនាំឱ្យយើងលាក់ខ្លួន ឱ្យយើងជាប់នៅក្នុងបន្ទប់ចាក់សោរ តែផ្ទុយទៅវិញឱ្យយើងទៅជាអ្នកបម្រើ ដែលព្រះជាម្ចាស់មានព្រះបន្ទូលថា "**យើងជាអ្នកបម្រើល្អដែលបានយកចិត្តទុកដាក់អស់ពីសមត្ថភាពដើម្បីរស់នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងអនុវត្តព្រះបន្ទូលនេះនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង**"។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ